ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF TOURISM

ក្រសួងទេសចរណ៍

លេខ...០០១...ទស.ណែន

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០៧..

# សារាចរណែនាំ

## ស្តីពី

## ការគ្រប់គ្រងអាជីវកម្មទីភ្នាក់ងារទេសចរណ៍

ដើម្បីគ្រប់គ្រងអាជីវកម្មទីភ្នាក់ងារទេសចរណ៍អោយមានសណ្តាប់ធ្នាប់ របៀបរៀបរយ ប្រកបដោយសន្តិសុខ សុវត្ថិភាព សុជីវធម៌ជូន ទេសចរជាតិ-អន្តរជាតិ និងក្នុងគោលបំណងធានាការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ថែរក្សាការពារវប្បធម៌ ប្រពៃណីជាតិ តាមគោលនយោបាយ អភិវឌ្ឍន៍វិស័យទេសចរណ៍របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង ដើម្បីអនុវត្តប្រកាសលេខ ០៦១ ប្រ.ក ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ដល់ អាជីវកម្មទីភ្នាក់ងារទេសចរណ៍ ក្រសួងទេសចរណ៍ សូមធ្វើការណែនាំដូចខាងក្រោម៖

១ ៖ រាល់ការធ្វើអាជីវកម្មទីភ្នាក់ងារទេសចរណ៍ និងសាខា ម្ចាស់ ឬអ្នកទទួលខុសត្រូវគ្រប់គ្រង ត្រូវមានច្បាប់អនុញ្ញាតពីក្រសួងទេសចរណ៍ ។ ទំរង់បែបបទនៃការសុំធ្វើអាជីវកម្មត្រូវបំពេញដោយម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មទីភ្នាក់ងារទេសចរណ៍ ឬសាខា និងត្រូវអនុវត្តតាមប្រកាសរបស់ក្រសួងទេសចរណ៍ ដោយភ្ជាប់មកជាមួយនូវឯកសារផ្សេងៗទៀតដែលក្រសួងទេសចរណ៍ត្រូវការរួមមាន ៖

- កិច្ចសន្យារបស់ម្ចាស់អាជីវកម្មចំពោះក្រសួងទេសចរណ៍ ក្នុងការប្រកបអាជីវកម្មទីភ្នាក់ងារទេសចរណ៍ និង សាខា
- ការបំពេញតារាងត្រួតពិនិត្យមូលដ្ឋានអាជីវកម្ម

២ ៖ ក្នុងការធ្វើអាជីវកម្ម ម្ចាស់ ឬអ្នកទទួលខុសត្រូវគ្រប់គ្រងអាជីវកម្មទីភ្នាក់ងារទេសចរណ៍ និងសាខា ត្រូវគោរពអនុវត្តតាមសារាចរណែនាំ និងបទប្បញ្ញត្តិស្តីអំពីអាជីវកម្មទីភ្នាក់ងារទេសចរណ៍ ច្បាប់ការងារ ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទៀតរបស់រដ្ឋដែលពាក់ព័ន្ធទៅនឹងការធ្វើអាជីវកម្មទេសចរណ៍ ដើម្បីជាកិច្ចធានាដល់សន្តិសុខ សុវត្ថិភាព សុខុមាលភាពជូនទេសចរ ។

៣ ៖ រាល់ការធ្វើអាជីវកម្មទីភ្នាក់ងារទេសចរណ៍ និងសាខា ត្រូវធានាថាមិនធ្វើអោយប៉ះពាល់ដល់ វប្បធម៌ ប្រពៃណីជាតិ សណ្តាប់ ធ្នាប់សាធារណៈ បរិស្ថាន និង របៀបរៀបរយសង្គម ។

៤ ៖ ត្រូវមានការិយាល័យទីស្នាក់ការសមស្រប មានការរៀបចំល្អត្រឹមត្រូវ និងត្រូវដាក់តាំងបង្ហាញអាជ្ញាប័ណ្ណទេសចរណ៍នៅក្នុងការិយាល័យទីស្នាក់ការក្រុមហ៊ុន កន្លែងដែលភ្ញៀវអាចមើលឃើញបានដោយស្រួល ។

៥ ៖ ត្រូវផ្តល់ដំណឹងជាលាយល័ក្ខអក្សរជូនក្រសួងទេសចរណ៍ពេលមានការផ្លាស់ប្តូរទីតាំង បិទអាជីវកម្ម ផ្លាស់ប្តូរឈ្មោះម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្ម ឈ្មោះនាមករណ៍ក្រុមហ៊ុន លេខទូរស័ព្ទ ទូរសារ និងព័ត៌មានលំអិតផ្សេងៗទៀតដែលក្រសួង ឬមន្ទីរទេសចរណ៍ត្រូវការ ។

៦ ៖ ដើម្បីពង្រឹងនូវលក្ខណៈសម្បត្តិ និងគុណភាពសេវាកម្ម ម្ចាស់ ឬអ្នកទទួលខុសត្រូវគ្រប់គ្រងត្រូវ៖

- គោរព និងអនុវត្តតាមគោលការណ៍ណែនាំរបស់ក្រសួងទេសចរណ៍ ។
- គោរព និងអនុវត្តតាមបទដ្ឋានបច្ចេកទេស ស្តង់ដារវិជ្ជាជីវៈអាជីវកម្មទីភ្នាក់ងារទេសចរណ៍ និងយកចិត្តទុកដាក់ទទួលខុសត្រូវខ្ពស់លើសន្តិសុខ សុវត្ថិភាពទេសចរ ។
- ប្រើប្រាស់មគ្គុទ្ទេសក៍ទេសចរណ៍ដែលមានអាជ្ញាប័ណ្ណទេសចរណ៍ មានសុពលភាព និងឯកសណ្ឋានត្រឹមត្រូវតាមការកំណត់របស់ក្រសួងទេសចរណ៍ ។
- ប្រើប្រាស់មធ្យោបាយដឹកជញ្ជូនទេសចរដែលមានគុណភាព និងមានប័ណ្ណធានារ៉ាប់រង ។
- ត្រូវផ្តល់ជូនភ្ញៀវជាអតិថិជននូវសេវាកម្មល្អសមស្របទៅតាមកម្មវិធីដែលក្រុមហ៊ុនបានផ្សព្វផ្សាយ ។
- ផ្តល់ព័ត៌មានជូនទេសចរអោយបានត្រឹមត្រូវ សមស្របតាមគោលនយោបាយទេសចរណ៍ជាតិ ។
- មានបទបញ្ជាផ្ទៃក្នុង ណែនាំបណ្តុះបណ្តាលដល់បុគ្គលិក និងមគ្គុទ្ទេសក៍នៅក្នុងទីភ្នាក់ងារទេសចរណ៍ អោយយល់ដឹងអំពីការងារបដិសណ្ឋារកិច្ច និងគ្រប់គ្រងទេសចរ ។
- ត្រូវជួយផ្សព្វផ្សាយដល់បុគ្គលិក និងទេសចរ នូវគោលការណ៍ណែនាំរបស់ក្រសួងទេសចរណ៍ ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិផ្សេងៗដែលទាក់ទងនឹងការជួញដូរគ្រឿងញៀន និងការកេងប្រវ័ញ្ចជួញដូរផ្លូវភេទលើកុមារ ។
- ទីភ្នាក់ងារទេសចណ៍ និងសាខា ត្រូវរៀបចំជាទម្រង់បែបបទ និងផ្តល់ជូនក្រសួងទេសចរណ៍នូវរាល់កម្មវិធីផ្សព្វផ្សាយអំពីកញ្ចប់ទស្សនកិច្ច ឬកម្មវិធីលំអិតខ្សែទស្សកិច្ចដែលរៀបចំតាមរដូវកាល ឬប្រចាំឆ្នាំដោយមានបញ្ជាក់ច្បាស់លាស់អំពីនាមករណ៍ក្រុមហ៊ុនទេសចរណ៍ រយៈពេលនៃទស្សកិច្ចនិមួយៗ តម្លៃសេវាប្រភេទយានយន្តដែលប្រើប្រាស់នៅក្នុងកម្មវិធី គោលដៅទស្សនាចរ ទីកន្លែងឈប់ចត រួមបញ្ចូលទាំងកន្លែងដែលទេសចរត្រូវទស្សនា ប្រភេទសេវាស្នាក់នៅ និងម្ហូបអាហារដែលត្រូវផ្តល់ជូនភ្ញៀវ ។

៧ ៖ ដើម្បីជៀសវាងពន្យល់ខុសពីវប្បធម៌ និងប្រវត្តិសាស្ត្រខ្មែរ ការប្រើប្រាស់មគ្គុទ្ទេសក៍ទេសចរណ៍ជាជនបរទេសត្រូវហាមឃាត់ ។ ករណីភាសា បរទេសណាមួយដែលក្រសួងទេសចរណ៍ពុំទាន់បណ្តុះបណ្តាលបាន ទីភ្នាក់ងារទេសចរណ៍និងសាខា ចាំបាច់ត្រូវយកមគ្គុទ្ទេសក៍ទេសចរណ៍កម្ពុជាមកពន្យល់អំពីប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណី ទំនៀមទំលាប់ខ្មែរជាមុន ដោយប្រើប្រាស់ភាសាអន្តរជាតិណាមួយ ហើយប្រធានក្រុមទេសចរជាអ្នកបកប្រែបន្តទៅអោយភ្ញៀវរបស់ខ្លួន ។

៨ ៖ រាល់សកម្មភាពធ្វើអាជីវកម្មជួញដូរគ្រឿងញៀន ការកេងប្រវ័ញ្ចជួញដូរផ្លូវភេទកុមារ អំពើពេស្យាចារគ្រប់ប្រភេទជ្រកក្រោមរូបភាពទីភ្នាក់ងារទេសចរណ៍ និងសាខា ត្រូវហាមឃាត់ជាដាច់ខាត ។ ហាមមានអាវុធជាតិផ្ទុះនៅទីកន្លែងអាជីវកម្ម ។

៩ ៖ ក្នុងករណីមិនគោរពតាមសារាចរណែនាំ ច្បាប់ និងបទប្បញ្ញត្តិ ស្តីពីការធ្វើអាជីវកម្មទីភ្នាក់ងារទេសចរណ៍ និងសាខា ម្ចាស់ ឬអ្នកទទួលខុសត្រូវគ្រប់គ្រងនឹងត្រូវទទួលនូវការផ្អាក ដកហូតអាជ្ញាប័ណ្ណទេសចរណ៍ ផាកពិន័យ ឬ

ទទួលខុសត្រូវតាមច្បាប់រដ្ឋកំណត់ ។ ករណីធ្វើអោយប៉ះពាល់ធ្ងន់ធ្ងរដល់សុវត្ថិភាព ឬបង្កអោយមានគ្រោះថ្នាក់ដល់ភ្ញៀវ ត្រូវទទួលទោសតាមច្បាប់រដ្ឋជាធរមាន ។

១០: ម្ចាស់ ឬអ្នកទទួលខុសត្រូវគ្រប់គ្រងទីភ្នាក់ងារទេសចរណ៍ និងសាខា ត្រូវសហការ និងរាយការណ៍ជាបន្ទាន់ជូនអាជ្ញាធរមានសមត្ថកិច្ច និងមន្ទីរទេសចរណ៍នូវរាល់បាតុភាពមិនប្រក្រតី ដែលបានកើតឡើងធ្វើអោយប៉ះពាល់ដល់សុវត្ថិភាពទេសចរ ឬការបង្កឡើងដោយទេសចរធ្វើអោយប៉ះពាល់ដល់របៀបរៀបរយសន្តិសុខ សណ្តាប់ធ្នាប់សង្គម ។

១១: ម្ចាស់ ឬអ្នកទទួលខុសត្រូវគ្រប់គ្រងទីភ្នាក់ងារទេសចរណ៍ និងសាខា ត្រូវមកបំពេញបែបបទដាក់ពាក្យស្នើសុំបើកអាជីវកម្មដំបូង និងបន្តតាមរយៈមន្ទីរទេសចរណ៍ខេត្ត-ក្រុង ដែលត្រូវពិនិត្យ និងអនុញ្ញាតដោយក្រសួងទេសចរណ៍ ។

១២: មន្ទីរទេសចរណ៍ខេត្ត-ក្រុង ត្រូវធ្វើការសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ត្រួតពិនិត្យទៅលើអាជីវកម្ម ដែលប្រព្រឹត្តផ្ទុយនឹងគោលការណ៍របស់ក្រសួងទេសចរណ៍ និងច្បាប់របស់រដ្ឋ ព្រមទាំងរាយការណ៍មកក្រសួងទេសចរណ៍ ។

១៣: មន្ទីរទេសចរណ៍ខេត្ត-ក្រុង ត្រូវអនុវត្តអោយបានម៉ឺងម៉ាត់តាមគោលការណ៍កំណត់របស់ក្រសួងទេសចរណ៍ ។

ទទួលបាននូវសារាចរណែនាំនេះ មន្ទីរទេសចរណ៍ខេត្ត-ក្រុង ត្រូវសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ និងអាជ្ញាធរដែនដីធ្វើការផ្សព្វផ្សាយណែនាំដល់គ្រប់អាជីវករ ទទួលអនុវត្តអោយមានប្រសិទ្ធភាពខ្ពស់ ដើម្បីរួមចំណែកបំរើវិស័យទេសចរណ៍កម្ពុជាអោយអភិវឌ្ឍន៍បានកាន់តែល្អប្រពៃ ។

រដ្ឋមន្ត្រី

ថោង ខុន

កន្លែងទទួលៈ

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការ គណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលា ខេត្ត-ក្រុង "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរទេសចរណ៍ ខេត្ត-ក្រុង "ដើម្បីមុខការ"
- គ្រប់ក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ